# មេរៀនទី ១១៥: ព្រះយេស៊ូវយាងដើរលើទឹក

## ម៉ាថាយ ៥:១៣-១៦

**គោលបំណង៖** ព្រះយេស៊ូវតែងតែខ្វល់ពីយើងសូម្បីតែពេលយើងសង្ស័យក៏ដោយ។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ១៤:៣៣** *"ឯពួកអ្នកដែលនៅក្នុងទូក ក៏មកថ្វាយបង្គំទ្រង់ទូលថា ទ្រង់ប្រាកដជា ព្រះរាជបុត្រានៃព្រះមែន។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលអ្នកទុកចិត្តលើព្រះយេស៊ូវនោះអ្នកអាច "ដើរលើទឹកបាន។" ព្រះយេស៊ូវប្រទានឱ្យអ្នកនូវសមត្ថភាព ដើម្បីសម្រេចនូវអ្វីដែលមិនអាចទៅរួចដែលផ្តល់ឱ្យទ្រង់នូវការយកចិត្តទុកដាក់ ដែលព្រះអង្គសមនឹងទទួលបាន។ សូមអានព្រះគម្ពីរ **ម៉ាថាយ ១៤:២២-៣៣** សារឡើងវិញ។ តើអ្នកអាចមើលឃើញស្ថានភាពមួយណា ដែលធ្វើឲ្យអ្នកមានការភ័យខ្លាចដ៏លើសលប់នោះ? តើអ្នកអាចទុកចិត្តព្រះបានដោយរបៀបណាដើម្បីឲ្យអ្នកអាច"ដើរ"ឆ្លងកាត់ព្យុះដែលមានក្នុងជីវិតអ្នកបាន? ព្រះយេស៊ូវនឹងឆ្លើយតបជាមួយអ្នក ដោយការស្រលាញ់និងការគាំទ្រ ដូចជាអ្វីដែលទ្រង់បានផ្តល់ឲ្យពេត្រុសអីចឹងដែរ។ ព្រះអង្គចង់ផ្តល់ឲ្យកូនរបស់ទ្រង់ទាំងអស់មានការលូតលាស់ខាងឯសេចក្តីជំនឿ។

**ចំរៀង៖** ១. បើទ្រង់គង់ជាមួយ ២. គឺជាការល្អ ៣. ពេលខ្យល់ព្យុះបក់ខ្លាំង

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «ជំហានតាមម៉ោង»**




១. ឲ្យកុមារណាម្នាក់(អាចជាកុមារដែលមានមាឌធំជាងគេក៏បាន) ស្ម័គ្រចិត្តធ្វើជាព្រះយេស៊ូវ ហើយឈរនៅចុងម្ខាងនៃថ្នាក់រៀន

២. កុមារដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវឈរនៅចុងម្ខាងទៀតនៃថ្នាក់រៀន ហើយពួកគេអាចផ្លាស់ទីបាន នៅពេលដែលគ្រូនិយាយលេខណាមួយនៃម៉ោង។ ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា "ម៉ោង៣" នោះមានន័យថាពួកគេអាចដើរបាន ៣ជំហាន។ ប្រសិនបើគ្រូនិយាយថា "ម៉ោង៥" នោះកុមារអាចដើរបាន៥ជំហាន។

៣. គោលបំណងនៃល្បែងនេះគឺដើម្បីចូលទៅជិតព្រះយេស៊ូវហើយប៉ះទ្រង់បាន

៤.កុមារទី១ដែលអាចប៉ះព្រះយេស៊ូវបានមុនគេកុមារនោះជាអ្នកឈ្នះល្បែងនេះ។ ប៉ុន្តែយើងនឹងបន្តលេងល្បែងនេះ រហូតដល់កុមារគ្រប់គ្នាៗបានប៉ះព្រះយេស៊ូវ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះយេស៊ូវស្រលាញ់យើង ទោះបីជាយើងមានការសង្ស័យក៏ដោយ។



## ៤. ការណែនាំមេរៀន

តើការសង្ស័យមានន័យដូចម្តេច? វាគឺមានន័យថា ការដែលមិនច្បាស់ទៅលើអ្វីមួយ។ ប្រហែលជាអ្នកមានការសង្ស័យទៅលើមិត្តភក្តិរបស់អ្នកថាគេនឹងរក្សាការសន្យាឬអត់។ ឬក៏អ្នកមានការសង្ស័យចំពោះខ្លួនអ្នកថា អាចរក្សាការសន្យាជាមួយឪពុកម្តាយរបស់អ្នកបានឬអត់។ វាគឺមានន័យថាអ្នកមិនប្រាកដអំពីរឿងនោះ។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ ដែលបានធ្វើនូវរឿងដ៏អស្ចារ្យនៅពេលដែលគាត់គ្មានការសង្ស័យ ប៉ុន្តែគាត់ធ្វើដោយជំនឿ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយព្រះយេស៊ូវបានបង្គំឲ្យពួកសិស្សចុះទូក ហើយជិះឆ្លងទៅត្រើយម្ខាងនៃសមុទ្រកាលីឡេមុនទ្រង់ ព្រោះទ្រង់គង់នៅទីនោះនិងកំពុងអធិស្ឋាន។ នៅពេលដែលសិស្សទាំងអស់នៅលើទូកនោះ ក៏មានព្យុះមកដល់! ពួកសិស្សមានការភ័យខ្លាចជាខ្លាំង។ ព្រះយេស៊ូវបានចំណាយពេលអធិស្ឋានយ៉ាងយូរ ពីព្រោះព្រះគម្ពីរបាននិយាយថាទ្រង់បានយាងទៅជួបពួកសិស្ស "នៅមុនពេលព្រឹកព្រលឹម។"

ប៉ុន្តែពួកសិស្សគឺនៅកណ្តាលសមុទ្រ ដូច្នេះតើព្រះយេស៊ូវអាចទៅរកពួកសិស្សបានដោយរបៀបណា? ព្រះគម្ពីរបាននិយាយថា ព្រះយេស៊ូវបានដើរលើទឹកដើម្បីទៅឯពួកគេ។ ពួកសិស្សមានការភ័យខ្លាចនៅពេលដែលពួកគេបានឃើញព្រះយេស៊ូវឈរនៅលើទឹក ព្រោះពួកគេគិតថាទ្រង់គឺជាខ្មោច! នៅពេលដែលព្រះយេស៊ូវប្រាប់ថាគឺជាទ្រង់ ពេត្រុសបាននិយាយថា ប្រសិនបើជាព្រះយេស៊ូវមែនសូមជួយខ្ញុំអាចដើរនៅលើទឹកផង។

ដូច្នេះ ព្រះយេស៊ូវបានប្រាប់ពេត្រុសឲ្យមក ហើយពេត្រុសក៏ដើរនៅលើទឹកបាន! តើវាពិតជាអស្ចារ្យណាស់ឬ? នៅពេលដែលពេត្រុសផ្តោតទៅលើព្រះយេស៊ូវ គាត់ក៏អាចដើរនៅលើទឹកបានដែរ។ ប៉ុន្តែនៅពេលដែលគាត់បានឃើញព្យុះ និងរលកសមុទ្រគាត់មានការសង្ស័យ។ គាត់ក៏ចាប់ផ្តើមមិនច្បាស់ក្នុងចិត្តថា តើគាត់គួរបន្តដើរទៀតឬអត់។ នោះហើយជាពេលដែលគាត់ចាប់ផ្តើមលិចចូលទៅក្នុងទឹក។ ព្រះយេស៊ូវក៏ប្រញាប់សង្គ្រោះគាត់ និងបានសួរគាត់ថា "ហេតុអ្វីបានជាអ្នកមានការសង្ស័យ?" ពេត្រុសមានការសង្ស័យ នៅពេលដែលគាត់ឈប់មើលទៅឯព្រះ ហើយផ្តោតទៅលើលោកីយ៍វិញម្តង។

យើងអាចជឿទុកចិត្តលើព្រះយេស៊ូវ ហើយយើងក៏អាចមានចិត្តសង្ស័យនឹងទ្រង់ក្នុងពេលតែមួយផងដែរ។ សូម្បីតែមនុស្សចាស់ក៏នៅតែមានការសង្ស័យចុះទម្រាំយើងដែលជាក្មេង។ យើងមិនចាំបាច់មានអារម្មណ៍ថាធ្វើខុសនោះទេ នៅពេលដែលយើងសង្ស័យទៅលើព្រះ ឬពីអ្វីដែលទ្រង់អាចធ្វើបានឬអត់នោះ។ អ្នកគ្រាន់តែមានចិត្តស្មោះត្រង់ជាមួយទ្រង់ប្រាប់ទ្រង់ពីអ្វីដែលអ្នកសង្ស័យ និងភ័យខ្លាច។ ព្រះទ្រង់នឹងយល់។

ការសង្ស័យរបស់ពួកយើងនឹងមានពេលមកនិងពេលទៅ ប៉ុន្តែវាមិនអាចផ្លាស់ប្តូរថា នរណាជាព្រះពិតប្រាកដបានទេ។ ពួកយើងប្រៀបបានដូចជាធូលីដីដែលម្តងបក់ទៅទីនេះ ឬនៅទីនោះ។ ប៉ុន្តែព្រះគឺប្រៀបបាននឹងថ្ម ដែលរឹងមាំនិងច្បាស់លាស់។ អ្នកមិនអាចផ្លាស់ប្រែទ្រង់បានទេ ហើយអ្នកក៏មិនអាចផ្លុំទ្រង់ឲ្យទៅឆ្ងាយបានដែរ។ នៅពេលដែលពេត្រុសមានការសង្ស័យទ្រង់បានមកដល់នឹងសង្គ្រោះគាត់។ ព្រះតែងតែយកចិត្តទុកដាក់និងឈរយ៉ាងរឹងមាំ បើទោះបីជាយើងមានការសង្ស័យក៏ដោយ ដូច្នេះនៅទីបំផុតយើងក៏អាចឈរមាំបាន។

**៦. សំនួរពិភាក្សា**

១. តើព្រះយេស៊ូវកំពុងធ្វើអ្វីនៅពេលដែលពួកសិស្សជិះទូកចេញទៅ? *ព្រះយេស៊ូវកំពុងតែអធិស្ឋាន*

២. តើព្រះយេស៊ូវទៅរកពួកសិស្សដោយរបៀបណា? *ទ្រង់ដើរលើទឹក*

៣. តើនរណាដែលបានសុំព្រះយេស៊ូវឲ្យគាត់អាចដើរលើទឹកដែរនោះ? *ពេត្រុស*

៤. ហេតុអ្វីបាជាគាត់លិចចូលទៅក្នុងទឹកនៅពេលដែលគាត់កំពុងដើរនោះ?
*គាត់ឈប់ផ្ដោតលើព្រះយេស៊ូវ និងមានការសង្ស័យនៅពេលដែលគាត់ឃើញខ្យល់ និងរលក*

៥. តើអ្នកត្រូវធ្វើដូចម្ដេចនៅពេលដែលអ្នកមានការសង្ស័យចំពោះព្រះ? *ប្រាប់ទ្រង់តាមត្រង់ ពីព្រោះព្រះតែងតែយល់ពីយើង និងនៅតែស្រលាញ់យើង មិនថាពេលដែលអ្នកមានការសង្ស័យក៏ដោយ*

**៧. ល្បែងកំសាន្ត** «ជិះទូក»




១. ឲ្យកុមារគ្រប់គ្នាឈរនៅកណ្ដាលថ្នាក់រៀន

២. កុមារត្រូវរត់រកគ្នាតាមចំនួន លេខដែលគ្រូហៅ។ ឧទាហរណ៍៖ នៅពេលដែលគ្រូនិយាយថា "ជិះទូក២នាក់" កុមារត្រូវរកដៃគូរពីរៗនាក់ហើយឈរកាន់ដៃគ្នា។ ប្រសិនបើគ្រូនិយាយថា "ជិះទូកគ្នា ៧នាក់" នោះកុមារត្រូវរត់រកគ្នាឲ្យបាន៧នាក់ហើយឈរជាមួយគ្នា។

៣. ប្រសិនបើកុមារមិនអាចស្វែករកដៃគូរឲ្យបានដូចលេខដែលគ្រូនិយាយទេនោះ នោះពួកគេនឹងចាញ់ល្បែងនេះ

៤. បន្តលេងល្បែងនេះរហូតនៅសល់កុមារតែ២នាក់ នោះពួកគេជាអ្នកឈ្នះល្បែងនេះ។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះអង្គគង់នៅក្នុងទូកដែលពួកយើងកំពុងជិះ។ ព្រះនឹងដឹកនាំយើង ហើយជួយយើងឲ្យឆ្លងកាត់សមុទ្រនោះបាន។

**៨. ខគម្ពីរចងចាំ** ម៉ាថាយ ១៤:៣៣

**៩. ហត្ថកម្ម** «ព្រះយេស៊ូវដើរលើទឹក»



**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម កូល័រ កន្ត្រៃ ដងឈើការ៉េម និងការបិត

១. ផាត់ពណ៌រូបព្រះយេស៊ូវ និងទូក

២. កាត់តាមបន្ទាត់រាងចតុកោណកែងជុំវិញទូក និងកាត់បន្ទាត់ខ្មៅជិត ដែលនៅពីមុខទូក

៣. កាត់រូបព្រះយេស៊ូវ និងបិតដងឈើការ៉េម ភ្ជាប់ជាមួយរូបព្រះយេស៊ូវផ្នែកខាងក្រោយ

៤. ដាក់រូបព្រះយេស៊ូវកាត់តាមបន្ទាត់ជិតខ្មៅ ដែលបានកាត់នៅពីមុខទូកនោះ ឥឡូវនេះព្រះយេស៊ូវអាចដើរលើទឹកទៅរកទូកបាន!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះយេស៊ូវយាងដើរលើទឹក







១. ផាត់ពណ៌រូបព្រះយេស៊ូវ និងទូក

២. កាត់តាមបន្ទាត់រាងចតុកោណកែងជុំវិញទូក និងកាត់បន្ទាត់ដិតដែលនៅពីមុខទូក

៣. កាត់រូបព្រះយេស៊ូវ និងបិតដងឈើការ៉េម ភ្ជាប់ជាមួយរូបព្រះយេស៊ូវផ្នែកខាងក្រោយ

៤. ដាក់រូបព្រះយេស៊ូវកាត់តាមបន្ទាត់ដិតខ្មៅ ដែលបានកាត់នៅពីមុខទូកនោះ

ឥឡូវនេះព្រះយេស៊ូវអាចដើរលើទឹកទៅរកទូកបាន!